**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បញ្ញត្តិករទូរគមនាគមន៍កម្ពុជា**

លេខ :..០៧៥២...ប.ក.ទ.ក.

**សូមជម្រាបមក**

**ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី**

**ប្រធានក្រុមហ៊ុនអាជីវកម្មផ្តល់សេវាទូរគមនាគមន៍**

**កម្មវត្ថុ** : សេចក្តីណែនាំស្តីពីការតភ្ជាប់បណ្តាញឆ្លងកាត់បមាណីទូរស័ព្ទ (Transit Switch) នៃទូរគមនាគមន៍កម្ពុជា ( Telecom Cambodia ) ។

**យោង** :
- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ស្តីពីវិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រតិបត្តិករទូរស័ព្ទមួយទៀត
- ប្រកាសលេខ២០៦ ប.ទ.ប្រក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីលើលិខិតលេខ ៧០៩៧ ស.ហ.វ. ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា សូមជម្រាបមក ឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនអាជីវកម្មផ្តល់សេវាទូរគមនាគមន៍ទាំងអស់ឲ្យបានជ្រាបថា ដោយអនុវត្តតាមបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ស្តីពីវិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រតិបត្តិករទូរស័ព្ទមួយទៀត និងប្រកាសលេខ២០៦ ប.ទ.ប្រក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍ និងលិខិតលេខ ៧០៩៧ ស.ហ.វ. ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងបញ្ជាក់ច្បាស់ថា ៖

១) ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវឆ្លងកាត់តាមមជ្ឈមណ្ឌលកណ្តាល ឬបមាណីទូរស័ព្ទនៃទូរគមនាគមន៍កម្ពុជា។

២) រាល់ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវចុះកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់បណ្តាញស្របតាមបទប្បញ្ញត្តិ។

៣) មិនអនុញ្ញាតឲ្យប្រតិបត្តិករទូរគមនាគមន៍តភ្ជាប់បណ្តាញរវាងគ្នាដោយផ្ទាល់ និងមិនឆ្លងកាត់មជ្ឈមណ្ឌលកណ្តាល ឬបមាណីទូរស័ព្ទនៃទូរគមនាគមន៍កម្ពុជា មុននឹងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (DMC) ដាក់ឲ្យដំណើរការជាផ្លូវការ ១០០%។

ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន បញ្ញត្តិករទូរគមនាគមន៍កម្ពុជាបានសង្កេតឃើញថា មានប្រតិបត្តិករស្ទើរតែទាំងអស់បានធ្វើការតភ្ជាប់បណ្តាញរវាងគ្នាទៅវិញទៅមកដោយផ្ទាល់ (Direct Connection) និងដោយពុំបានឆ្លងកាត់មជ្ឈមណ្ឌលកណ្តាល ឬបមាណីទូរស័ព្ទនៃទូរគមនាគមន៍កម្ពុជា ១០០% ឡើយ ។ ព្រោះថានៅពេលធ្វើការផ្ទៀងផ្ទាត់នូវទិន្នន័យចរន្តត្រាហ្វិកនៅក្នុងរបាយការណ៍របស់ទូរគមនាគមន៍កម្ពុជា និងរបាយការណ៍របស់

ប្រតិបត្តិករនីមួយៗ ដែលបានផ្តល់ជូនមកបញ្ញត្តិករទូរគមនាគមន៍កម្ពុជាមានលំអៀង ២% នៅឆ្នាំ២០១០ ១២%នៅឆ្នាំ២០១១ និង ២៥% ទៅ ៣០% ក្នុងឆ្នាំ ២០១២ / ២០១៣ ។ ការអនុវត្តទង្វើបែបនេះរបស់ប្រតិបត្តិករគឺផ្ទុយទៅនឹងបទបញ្ជាលេខ០១ បប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ស្តីពីវិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រតិបត្តិករទូរស័ព្ទមួយទៀត និងប្រកាសលេខ ២០៦ប.ទ.ប្រក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍ និងលិខិតលេខ៧០៩៧ ស.ហ.វ. ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលចេញដោយរាជរដ្ឋាភិបាល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយបានធ្វើឲ្យបាត់បង់ចំណូលជាតិដែលទទួលបានពីកម្រៃឆ្លងកាត់បមាណីទូរស័ព្ទនៃទូរគមនាគមន៍កម្ពុជាជាច្រើន ដែលការអនុវត្តនេះត្រូវបានចាត់ទុកថា ផ្ទុយពីច្បាប់ស្តីពីក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយនៃព្រះរាជាណាចក្រកម្ពុជាក្នុងការគេចប្រាញ់ថវិកាជាតិ។

ករណីនេះ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា សូមឲ្យបណ្តាប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវតែបញ្ឈប់ជាបន្ទាន់នូវការអនុវត្តផ្ទុយពីបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ស្តីពីវិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រតិបត្តិករទូរស័ព្ទមួយទៀត និងប្រកាសលេខ២០៦ ប.ទ.ប្រក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍ និងលិខិតលេខ ៧០៩៧ ស.ហ.វ. ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃចុះហត្ថលេខាលើសេចក្តីណែនាំនេះជាកំហិត ។ ក្នុងករណីមិនអនុវត្តតាម បញ្ញត្តិករទូរគមនាគមន៍កម្ពុជានឹងចាត់វិធានការទៅតាមនីតិវិធីផ្លូវច្បាប់ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនអាជីវកម្មផ្តល់សេវាទូរគមនាគមន៍ទាំងអស់ជ្រាប និងសហការអនុវត្តឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ។

សូមឯកឧត្តម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនអាជីវកម្មផ្តល់សេវាទូរគមនាគមន៍ទាំងអស់ទទួលនូវការរាប់អានអំពីខ្ញុំ ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៤

**ប្រធាន**

**ម៉ុង ចរិយា**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ